# រឿងភ្នំប្រុសភ្នំស្រី
នៅខេត្តកំពង់ចាម

បើយើងធ្វើដំណើរចេញពីក្រុងភ្នំពេញទៅកំពង់ចាម តាមផ្លូវជាតិលេខ ៧ ដល់ទៅគោលគីឡូម៉ែត្រទី ១១៦ ហើយបោលស្តែកទៅទិសត្បូង ដែលនៅជាខាងឆ្វេងដៃ ចម្ងាយពីថ្នល់ជាតិទៅប្រហែលជាមួយគីឡូម៉ែត្រ យើងនឹងឃើញភ្នំ ២ នៅទន្ទឹមគ្នា ១ ខាងកើតខ្ពស់ ១ ខាងលិចទាប ។ ភ្នំខ្ពស់ឈ្មោះភ្នំស្រី ភ្នំទាបឈ្មោះភ្នំប្រុស ។

រឿងព្រេងប្រចាំភ្នំនោះ មានដូចតទៅនេះ៖

កាលពីព្រេងនាយ មានស្តេចស្រីមួយព្រះអង្គព្រះនាម «ស្រីអយុធ្យា» សោយរាជ្យនៅនគរខ្មែរ ។ ដោយព្រះនាងជាស្តេចសោយរាជ្យ គ្មានបុរសណាមួយហ៊ានដណ្តឹងជាភរិយាឡើយ ម្ល៉ោះហើយ ព្រះនាងរកដណ្តឹងបុរសដ៏មានរូបជាទីគាប់ព្រះទ័យមកធ្វើជាព្រះស្វាមីវិញ ហើយដោយហេតុព្រះរាជនីស្រីអយុធ្យាដណ្តឹងប្រុសជាព្រះស្វាមីដូច្នោះ ស្រីៗ ដែលនៅក្រោមព្រះរាជោវាទព្រះនាងក៏ដណ្តឹងប្រុសៗ ធ្វើជាស្វាមីតាមដែរ ។

ក្នុងរជ្ជកាលនោះ មុខគួរឲ្យវេទនានឹងស្រីខ្លះដែលមានរូបអន់ៗ ទៅដណ្តឹងប្រុស ។ គេនាំប្រកែកមិនយក គេរើសតែស្រីៗ មានរូបល្អៗ ទើបយកធ្វើជាភរិយា ។ ធ្វើដូច្នេះ អស់មួយរាជ្យស្តេចស្រីនេះ ។ លុះដល់រាជ្យស្តេចក្រោយទៀត ពួកស្រីៗ ជំនុំគ្នាថា «ឥឡូវនេះ ដូចជាមិនសមសោះ ខ្លួនយើងជាស្រីហើយដើររកដណ្តឹងប្រុសៗ ធ្វើជាប្តី បើដូច្នេះយើងនឹងនាំគ្នាលើកដីចាក់ពូនជាភ្នំភ្នាល់ជាមួយនឹងពួកប្រុសៗ គឺប្រុសលើកដីធ្វើជាភ្នំមួយ យើងស្រីធ្វើជាភ្នំមួយ ភ្នាល់គ្នា ។ បើប្រុសៗ ចាញ់យើង ត្រូវឲ្យប្រុសៗ ដណ្តឹងយើងជាស្រីវិញ» ។ លុះគិតដូច្នេះហើយ ក៏នាំគ្នាទៅបបួលពួកប្រុសធ្វើភ្នំ ចុះៗ សន្យាភ្នាល់គ្នាដូចពោលមក ហើយគេក៏ច្បាធចាត់មេកំណែនកេណ្ឌ

មនុស្សស្រីឱ្យបានច្រើន ខាងប្រុសមានមេកំណែនខាងប្រុសលុះកេណ្ឌបានគ្នាច្រើន គ្រប់ចំនួនខាងប្រុស-ខាងស្រីរួចហើយក៏និយាយនឹងគ្នាថា «យើងទាំងអស់គ្នាត្រូវជញ្ជូនដីជរាបដល់ផ្កាយព្រឹករះទើបឈប់ទាំងអស់គ្នា បើផ្កាយព្រឹកមិនទាន់រះ មិនត្រូវឈប់ទេ» ។ គិតព្រមគ្នាដូច្នេះហើយក៏នាំគ្នាជញ្ជូនដី វែកទូលតាមឋាមភាពរៀងខ្លួនទៅ ។

ពេលនោះ ជាពេលរាត្រី ស្រីៗ មានប្រាជ្ញា ជញ្ជូនដីអស់វេលា ៣-៤ ម៉ោងក៏នាំគ្នាបង្ហូតគោមតូចមួយយ៉ាងខ្ពស់នៅជ្រុងឦសានភ្នំ ពួកប្រុសៗ ក្រឡេកមើលទៅលើឃើញគោមដែលស្រីបង្ហូតនឹងឫស្សីមួយដើមនោះ ស្មានថាផ្កាយព្រឹករះ ក៏បបួលគ្នាឈប់ធ្វើការនាំគ្នាដិទ្រាលក់អស់ទៅគ្មានសល់ម្នាក់ ពួកស្រីៗ ក៏នាំគ្នាជញ្ជូនដីជរាបដល់ផ្កាយព្រឹករះមែនទែន ទើបឈប់ ។

ដល់មាន់រងាវកឹត ប្រុសៗ ភ្ញាក់ឡើងឃើញផ្កាយព្រឹករះ ក៏លាន់មាត់ថា «យើងទាំងអស់គ្នាខុសហើយ ផ្កាយព្រឹកមែនទែនទើបតែនឹងរះសោះ» ហើយនាំគ្នាក្រឡេកមើលទៅភ្នំស្រីមានទំហំធំខ្ពស់ជាងភ្នំរបស់ខ្លួន ក៏មានសេចក្ដីអៀនអន់ក្នុងចិត្ត ដោយចាញ់កលស្រីៗ ។

តាំងពីកាលនោះមក ប្រុសៗ ក៏ដណ្ដឹងស្រីៗ ធ្វើជាភរិយាជរាបដល់សព្វថ្ងៃនេះ ។

## ពន្យល់ពាក្យ

ខែត្រ province; nowadays the spelling ខេត្ត is more commonly used

គោល post (refers to the kilometer marker post)

បោលភ្នែក cast a glance

ទិសឦសាន northeast (literary term; the everyday term is ខាងជើងឆៀងខាងកើត) Note that ទិស is used to mean “direction” when using Sanskrit-based literary terms; otherwise ខាង is used

ទន្ទឹមគ្នា next to each other; lined up together

ព្រះនាម name (royal)

សោយរាជ្យ to rule (literally “to eat the kingdom”)

ភរិយា wife (elegant term)

ម្ល៉ោះហើយ therefore

គាប់ព្រះទ័យ to be pleasing to (royal); for the rest of us we say គាប់ចិត្ត

ព្រះស្វាមី husband (elegant term) of a queen

ព្រះរាជិនី queen

ព្រះរាជោវាទ royal advice or teachings

រជ្ជកាល reign or rule

មុខគួរឲ្យ must be; here it means “must have been”

រូបអន់ៗ not very attractive

ប្រកែក to protest, to argue

អស់មួយរាជ្យ [the time of] one reign passed by

ជំនុំគ្នា got together

បាក់ពូន to pile up

ភ្នាល់ to bet or wager

ពោល to say (elegant)

ចាត់មេកំណែន appoint a corvee (conscription) supervisor

កេណ្ឌ to conscript or draft; to conscript as corvee labor (pronounsed កែន)

ជញ្ជូនដី to transfer dirt

ដរាបដល់ is an elegant term meaning រហូតដល់ until

រែក to carry two equal weights suspended on each end of a pole, with the pole resting across the shoulder (often used in transporting water, or here, dirt, in pails)

ទូល to carry on the head

ឫទ្ធានុភាព power

រាត្រី night (elegant term)

មានប្រាជ្ញា clever; wise

បង្ហូត to raise; lift; hoist

ជ្រុងឦសាន the northeast corner

ក្រឡេកមើល to glance

និទ្រា elegant term meaning ដេក

រងាវ to crow (said of a rooster)

គឹត sound of the rooster's crowing

ទើបតែ [verb] សោះ "only just now [verb]"

ភ្នំរបស់ខ្លួន "their own mountain"

មានសេចក្ដីអៀនអន់ to be embarrassed or ashamed